ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីប្រកាសព័ត៌មាន

## ឯកអគ្គរាជទូតកម្ពុជា ជួបពិភាក្សាការងារជាមួយប្រធានក្រុមហ៊ុន KOJIMA Holdings Group

នៅថ្ងៃទី២២ ខែមករា ឆ្នាំ ២០២៦ នៅទីក្រុងអាតស៊ូហ្គិ ខេត្តកាណាហ្គាវ៉ា **ឯកឧត្តម លោក ជុំ សុន្ទរី** ឯកអគ្គរាជទូតតែងតាំងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន បានជួបពិភាក្សាការងារជាមួយលោក **KOJIMA Masanobu** ប្រធានក្រុមហ៊ុន KOJIMA Holdings Co., Ltd. ។ ជំនួបនេះ ត្រូវបានធ្វើឡើងក្នុងបរិយាកាសស្និទ្ធស្នាល និងស្ថាបនា ដែលឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍រួមគ្នា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម រវាងប្រទេសកម្ពុជា និងប្រទេសជប៉ុនបន្ថែមទៀត។

នៅក្នុងជំនួបនេះ ឯកឧត្តមឯកអគ្គរាជទូត បានសម្តែងការកោតសរសើរយ៉ាងខ្លាំងចំពោះការចូលរួមយូរអង្វែង និងកំពុងបង្កើនការចូលរួមឥតឈប់ឈររបស់ក្រុមហ៊ុន KOJIMA Holdings Group ជាមួយប្រទេសកម្ពុជា។ ឯកឧត្តម បានសរសើរចំពោះការរួមចំណែករបស់ក្រុមហ៊ុន ចាប់តាំងពីការបង្កើតក្រុមហ៊ុន KOJIMAGUMI Cambodia Co., Ltd. ក្នុងឆ្នាំ២០១៣ រួមមានសកម្មភាពសាងសង់ កិច្ចសហប្រតិបត្តិការជាមួយ JICA និងស្ថាប័នជប៉ុនលើគម្រោងស្រាវជ្រាវ ព្រមទាំងការបណ្តុះបណ្តាល និងទទួលយកវិស្វករកម្ពុជាមកបម្រើការងារក្នុងប្រទេសជប៉ុន។ ក្នុងនោះដែរ ឯកឧត្តម ក៏បានស្វាគមន៍ចំពោះតួនាទីរបស់ក្រុមហ៊ុន ក្នុងការសម្របសម្រួលដល់ចលភាពធនធានមនុស្ស ក្នុងនាមជាអង្គការគាំពារដែលបានចុះបញ្ជីសម្រាប់កម្មករជំនាញជាក់លាក់ ក៏ដូចជាគំនិតផ្តួចផ្តើមនានារបស់ខ្លួន ក្នុងការពង្រឹងទំនាក់ទំនងរវាងប្រជាជន និងប្រជាជនកាន់តែខ្លាំងឡើង។

ឯកឧត្តមឯកអគ្គរាជទូត បានគូសបញ្ជាក់បន្ថែមអំពីសារៈសំខាន់ នៃមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា (Cambodia Private Commercial Center - CPCC) ដែលបានបង្កើតឡើងក្នុងឆ្នាំ២០២២ ជាវេទិកាដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍធនធានមនុស្ស ការផ្លាស់ប្តូរធុរកិច្ច និងវប្បធម៌ជាមួយទៅវិញទៅមក។ ឯកឧត្តម ក៏បានស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមថ្មីៗ និងសកម្មភាពនាពេលខាងមុខរបស់ក្រុមហ៊ុន រួមទាំងកិច្ចសហប្រតិបត្តិការជាមួយក្រសួងនានារបស់កម្ពុជា ក្នុងវិស័យដូចជា ការអភិវឌ្ឍលំនៅដ្ឋាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្លាស់ប្តូរវប្បធម៌។ ឯកឧត្តម បានគូសបញ្ជាក់ថា សិក្ខាសាលាធុរកិច្ចប្រចាំខែ ដែលរៀបចំដោយ KOJIMA Holdings Group ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយជំរុញផលិតផលកម្ពុជា ពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងលើកកម្ពស់បណ្តាញធុរកិច្ច រវាងពាណិជ្ជករកម្ពុជា និងជប៉ុន។

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh

ភាគីទាំងពីរ បានផ្លាស់ប្តូរទស្សនៈលើកិច្ចសហប្រតិបត្តិការកាន់តែទូលំទូលាយ ក្រោមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ជប៉ុន រួមទាំងកាលានុវត្តភាពដែលកើតចេញពីសេដ្ឋកិច្ចដែលកំពុងរីកចម្រើនរបស់កម្ពុជា និងកញ្ចប់សហបង្កើតសេដ្ឋកិច្ចជប៉ុន-កម្ពុជា។ នៅចុងបញ្ចប់ ឯកឧត្តមឯកអគ្គរាជទូត បានបញ្ជាក់ជាថ្មីអំពីការត្រៀមខ្លួនរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងតូក្យូ ក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុន KOJIMA Holdings Group ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក លើកកម្ពស់ពាណិជ្ជកម្ម និងវិនិយោគ និងពង្រឹងបន្ថែមទៀតនូវភាពជាដៃគូ រវាងកម្ពុជានិងជប៉ុន។

ថ្ងៃសុក្រ ៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
តូក្យូ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦